មើលវីដេអូ ភាគទី ៣១

# វិនិច្ឆ័យកាមេសុមិច្ឆាចារដោយអាការ ៥ ៖

| | |
|---|---|
| ១ - ដោយមូល | មានមូល២ គឺ លោភមូល និងមោហមូល |
| ២ - ដោយកម្ម | ជាកាយកម្ម |
| ៣ - ដោយទ្វារ | កើតតាមកាយទ្វារ |

៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ ៖

| | |
|---|---|
| - ប្រព្រឹត្តលើអ្នកដែលមិនមានឆន្ទៈរួមគ្នា | មានទោសច្រើន |
| - ប្រព្រឹត្តលើអ្នកដែលមានឆន្ទៈរួមគ្នា | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ កាមេសុមិច្ឆាចារមានអង្គ៤ គឺ ៖

- អគមនីយវត្ថុ — វត្ថុមិនគួរទាក់ទង (បានដល់ស្ត្រីដែលមានអ្នកហួងហែងរក្សា)
- តស្មឹ សេវនចិត្តំ — មានចិត្តគិតនឹងសេពនូវវត្ថុមិនគួរនោះ
- សេវនប្បយោគោ — ព្យាយាមក្នុងការសេព
- មគ្គេន មគ្គប្បដិបាទនំ — ញ៉ាំងមគ្គនិងមគ្គឲ្យដល់គ្នា។

** កាលណាគ្រប់អង្គទាំង៤ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*

# វិនិច្ឆ័យមុសាវាទដោយអាការ ៥ ៖

១- ដោយមូល មានមូល៣ គឺ លោភមូល ទោសមូល និងមោហមូល

២- ដោយកម្ម ជាវចីកម្ម

៣- ដោយទ្វារ សម្រេចតាមទ្វារ ២ គឺកាយទ្វារ និងវចីទ្វារ

## ៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះគឺ ៖

| | |
|---|---|
| - កុហកនាំឲ្យអ្នកដទៃខូចប្រយោជន៍ច្រើន | មានទោសច្រើន |
| - កុហកនាំឲ្យអ្នកដទៃខូចប្រយោជន៍តិច | មានទោសតិច |
| - កិលេសនិងការព្យាយាមខ្លាំង | មានទោសច្រើន |
| - កិលេសនិងការព្យាយាមខ្សោយ | មានទោសតិច |

## ៥ - ដោយអង្គ មុសាវាទមានអង្គ ៤ គឺ ៖

| | |
|---|---|
| - អតថំ វត្ថុ | វត្ថុ ឬរឿងមិនពិត |
| - វិសំវាទនចិត្តំ | គិតនឹងពោលឲ្យខុស |
| - តជ្ជោ វាយាមោ | ព្យាយាមនឹងពោលឲ្យខុស |
| - បរស្ស តទត្ថវិជាននំ | ញ៉ាំងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្តីនោះ ។ |